សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការញ៉ាំគុយទាវទឹកស៊ុប។ អញ្ចឹងការញ៉ាំគុយទាវទឹកស៊ុប គឺយើងអាចញ៉ាំបាននៅពេលព្រឹក ធ្វើជាអាហារពេលព្រឹក ហើយនិងពេលល្ងាចដែលយើងញ៉ាំជាអាហារសម្រន់។ អញ្ចឹងជាទូទៅគុយទាវទឹកស៊ុប យើងអត់សូវញ៉ាំពេលថ្ងៃនោះទេ ដោយសារតែពេលថ្ងៃយើងញ៉ាំបាយ ជាទូទៅនៅកម្ពុជាគឺយើងញ៉ាំបាយនៅពេលថ្ងៃ ហើយពេលល្ងាចក៏យើងញ៉ាំបាយដែរ ក៏ប៉ុន្តែពេលខ្លះមុនពេលអាហារពេលល្ងាច យើងអាចញ៉ាំមីស៊ុប ឬក៏គុយទាវ ដើម្បីជាអាហារសម្រន់។ អញ្ចឹងភាគច្រើនការញ៉ាំគុយទាវទឹកស៊ុបគឺយើងញ៉ាំនៅម៉ោងបួនល្ងាច ឬក៏ប្រាំល្ងាច ដែលអត់ទាន់ដល់ម៉ោងបាយទេ ព្រោះថាជាទូទៅនៅកម្ពុជាគឺជាមធ្យមម៉ោងបាយ គឺម៉ោងប្រាំមួយ ឬក៏ម៉ោងប្រាំពីរល្ងាច។ ដែលអញ្ចឹងដើម្បីកុំឲ្យឃ្លាន គឺយើងញ៉ាំអាហារសម្រន់សិន ហើយអាហារសម្រន់ដែលពេញនិយមនៅពេលល្ងាចគឺជាគុយទាវ ឬក៏មី ដែលមានទឹកស៊ុប ឬក៏ខគោ។ អញ្ចឹងពេលព្រឹកក៏យើងអាចញ៉ាំបានដែរ ពេលព្រឹក យើងអាចញ៉ាំជាអាហារពេលព្រឹក ក៏ប៉ុន្តែយើងអត់សូវញ៉ាំគុយទាវទឹកស៊ុបជាអាហារថ្ងៃត្រង់នោះទេ។

អញ្ចឹងយើងមកមើលរូបភាពទាំងអស់គ្នា ដោយរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានក្មេងប្រុសម្នាក់ ដែលអាយុគាត់ប្រហែលជា ១៨ ឆ្នាំ។ អញ្ចឹងយើងមើល ក្មេងប្រុសនោះ គឺគាត់ពាក់អាវដៃខ្លីពណ៌ស អាវគាត់មានកបើក។ អញ្ចឹងគាត់ពាក់អាវកបើក ដែលអាវកបើកនោះ បានន័យថាយើង អាវនោះមានក ហើយយើងអាចបត់បាន ហើយនៅ នៅខាងឆ្វេង នៅលើអាវខាងឆ្វេងរបស់គាត់គឺមានហោប៉ៅតូចមួយ អញ្ចឹងកូនហោប៉ៅតូចគឺយើងអាចដាក់លុយ ឬក៏ដាក់សម្ភារៈផ្សេងៗ ដែលតូចៗ នៅក្នុងហោប៉ៅនោះបាន។ ដែលជាទូទៅ សម្រាប់សិស្ស ឬក៏អ្នកធ្វើការនានា ហោប៉ៅអាវគេតែងតែដាក់ប៊ិច។ ប៉ុន្តែនៅក្នុងរូបភាពនេះ ក្មេងប្រុសម្នាក់នេះ គាត់អត់បានដាក់ប៊ិចនៅក្នុងហោប៉ៅទេ។ អញ្ចឹងអាវគាត់មានហោប៉ៅតូចមួយ សម្រាប់គាត់ដូចជាដាក់លុយ ឬក៏ដាក់ក្រដាសផ្សេងៗដែលតូចៗនៅក្នុងហោប៉ៅអាវនោះ។ អញ្ចឹងក្មេងប្រុសម្នាក់ហ្នឹង គាត់មានសក់ខ្លី ហើយគាត់កំពុងតែគិត។ អញ្ចឹងនៅក្នុងរូបភាពទី ១ នោះ យើងឃើញក្មេងប្រុសម្នាក់នោះ គាត់យកដៃម្ខាងច្រត់ចង្កេះ ហើយដៃម្ខាងទៀតចង្អុលទៅមាត់របស់គាត់ ដោយគាត់កំពុងតែគិត។ អញ្ចឹងដៃឆ្វេងគាត់ចង្អុលមាត់ រីឯដៃស្តាំរបស់គាត់ច្រត់ចង្កេះ ដែលយើងឃើញគាត់យកដៃដាក់លើចង្កេះ យើងហៅថាច្រត់ចង្កេះ។ ហើយគាត់កំពុងតែគិតអំពីមីទឹកស៊ុប អញ្ចឹងបានន័យថាគាត់កំពុងតែឃ្លាន ដែលនៅក្នុងរូបភាពនេះ គឺគាត់ឃ្លាន ហើយគាត់គិតថាគាត់ចង់ញ៉ាំទឹកស៊ុប ដោយយើងឃើញ នៅខាងលើគាត់ នៅខាងលើគាត់គឺយើងឃើញមានពពុះមួយ ដែលពពុះនោះគឺជាការគិតរបស់គាត់ អញ្ចឹងនៅក្នុងរូបភាពនេះ យើងឃើញមានចានគុយទាវ ឬក៏ចានមីទឹកស៊ុបមួយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលនៅក្នុងនោះមានសរសៃមី ឬក៏សរសៃគុយទាវ។ អញ្ចឹងជាទូទៅមីឬក៏គុយទាវ
គឺមានសរសៃវែងៗ ដែលសរសៃវែងៗនោះគឺនៅក្នុងចាន ដាក់ចានគោមមួយ យើងឃើញចានគោម
ដាក់សរសៃមីឬសរសៃគុយទាវ ដែលមានទឹកស៊ុបនៅក្នុងនោះ
ហើយយើងឃើញចាននោះកំពុងតែក្ដៅ អញ្ចឹងបានន័យថា រាល់ការញ៉ាំមី ឬក៏ញ៉ាំគុយទាវទឹកស៊ុប
គឺតែងតែមានទឹកស៊ុបក្ដៅ ដោយសារតែទឹកស៊ុបត្រជាក់យើងញ៉ាំអត់កើតទេ
អញ្ចឹងគេញ៉ាំជាមួយនឹងទឹកស៊ុបដែលក្ដៅ ដូច្នេះហើយ យើងឃើញចានមីដែលគាត់កំពុងគិតនោះ
គឺកំពុងតែហុយ។ ដែលបានន័យថាក្ដៅ ហើយវាមានក្លិនឈ្ងុយ ហើយយើងឃើញនៅលើចានទឹកមី
ឬក៏ទឹកស៊ុបនោះ យើងឃើញមានចង្កឹះមួយគូផងដែរ។ អញ្ចឹងចង្កឹះនេះគឺជាឧបករណ៍
យើងហៅថាឧបករណ៍សម្រាប់ចាប់មី។ អញ្ចឹងប្រសិនបើយើងញ៉ាំបាយ យើងប្រើស្លាបព្រា
ប៉ុន្តែបើយើងញ៉ាំមី ឬក៏ញ៉ាំគុយទាវគឺយើងប្រើចង្កឹះដើម្បីចាប់
ព្រោះស្លាបព្រាវាពិបាកចាប់ក្នុងការចាប់សរសៃមីណាស់ ដោយសារតែសរសៃមីវែង
ហើយស្លាបព្រាគឺសំប៉ែត អញ្ចឹងស្លាបព្រាសំប៉ែត ពិបាកនឹងចាប់សរសៃមីវែងណាស់
ដូច្នេះគេប្រើចង្កឹះមួយគូដើម្បីចាប់សរសៃមីងាយស្រួលជាង។ អញ្ចឹងនៅក្នុងរូបភាពនេះ
គឺក្មេងប្រុសម្នាក់ហ្នឹង គាត់កំពុងតែគិតអំពីមីទឹកស៊ុប ឬក៏គុយទាវទឹកស៊ុបដែលគាត់ចង់ញ៉ាំ
ដោយយើងឃើញគុយទាវទឹកស៊ុបនោះកំពុងតែហុយផ្សែង
ហើយនិងមានចង្កឹះមួយគូនៅលើចានផងដែរ។

បន្ទាប់មកទៀតរូបភាពទី ២ រូបភាពទី ២ បន្ទាប់ពីគាត់បានគិតទៅដល់មីទឹកស៊ុប
ដែលគាត់ចង់ញ៉ាំរួចរាល់ហើយ អញ្ចឹងគាត់ក៏បាននឹកទៅដល់មិត្តភក្តិរបស់គាត់ម្នាក់ទៀត
ដោយគាត់គិតចង់បបួលមិត្តភក្តិរបស់គាត់ទៅញ៉ាំមីទឹកស៊ុបទាំងអស់គ្នា
ព្រោះជាទូទៅការញ៉ាំអាហារបែបនេះ ប្រសិនបើយើងញ៉ាំម្នាក់ឯងគឺអត់សូវឆ្ងាញ់ទេ
អញ្ចឹងយើងញ៉ាំម្នាក់ឯងអត់សូវឆ្ងាញ់ទេ ដូច្នេះទាល់តែមានគ្នាទៅជាមួយទើបញ៉ាំឆ្ងាញ់
ដោយសារតែយើង នៅពេលដែលយើងមានគ្នា គឺយើងអាចនិយាយគ្នាលេង
ឬក៏ជជែកគ្នាលេងពីការសិក្សា ឬក៏ជជែកគ្នាពីការងារ
អញ្ចឹង[វា]ធ្វើឲ្យយើងមានបរិយាកាសកាន់តែរីករាយ ដូច្នេះគាត់ក៏បានទៅរកមិត្តភក្តិរបស់គាត់
អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់ក៏បានទៅរកមិត្តភក្តិរបស់គាត់ ដើម្បីបបួលគ្នាទៅញ៉ាំមីទឹកស៊ុប
ដោយយើងឃើញនៅក្នុងរូបភាពទី ២ គឺ យើងឃើញក្មេងប្រុសដែលមានអាយុប្រហែលជា ១៨
ឆ្នាំហ្នឹង គាត់ឈរនៅខាងស្ដាំ ហើយមិត្តភក្តិរបស់គាត់ឈរទល់មុខគាត់។ អញ្ចឹងគេ
ពួកគេទាំងពីរអ្នកឈរទល់មុខគ្នា ដោយយើងឃើញមិត្តភក្តិរបស់គាត់ហ្នឹងក៏ពាក់អាវដៃខ្លីពណ៌សដែរ
អញ្ចឹងពួកគេទាំងពីរអ្នកសុទ្ធតែពាក់អាវដៃខ្លីពណ៌ស ហើយប៉ុន្តែមិត្តភក្តិរបស់គេគឺមានសក់ខ្លី
ប៉ុន្តែសក់របស់គេគឺបះឡើងលើ អញ្ចឹងគាត់ធ្វើម៉ូតសក់បះឡើងលើ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយយើងឃើញសក់ខាងមុខរបស់គាត់ គឺសិតបះឡើងលើ។ អញ្ចឹងក្មេងប្រុសទី ១
គឺគាត់មានសក់រាប គាត់សិតរាប ក៏ប៉ុន្តែក្មេងប្រុសទី ២ ដែលជាមិត្តភក្តិរបស់គាត់
គឺគាត់សិតសក់បះឡើងលើ ហើយក្មេងប្រុសទី ១ ហ្នឹង
គាត់ក៏បាននិយាយប្រាប់ទៅមិត្តភក្តិរបស់គាត់ថាគាត់ចង់ញ៉ាំមីទឹកស៊ុប
ដោយគាត់យកមេដៃចង្អុលទៅខ្លួនគាត់។ អញ្ចឹងយើងឃើញដៃស្តាំរបស់គាត់ក្តាប់ម្រាមបួន
អញ្ចឹងម្រាមបួនរបស់គាត់គឺក្តាប់ចូលគ្នា ក៏ប៉ុន្តែយកមេដៃមួយដើម្បីចង្អុលមកខ្លួនឯង
អញ្ចឹងគាត់កំពុងតែនិយាយទៅប្រាប់មិត្តភក្តិរបស់គាត់ថា គាត់កំពុងតែឃ្លានមីទឹកស៊ុប
អញ្ចឹងគាត់អាចសួរទៅមិត្តភក្តិរបស់គាត់ថា ចង់ញ៉ាំមីទឹកស៊ុបដែរឬទេ? ឬក៏សួរមិត្តភក្តិរបស់គាត់ថា
តើចូលចិត្តញ៉ាំមីដែរឬទេ ឬក៏សួរមិត្តភក្តិរបស់គាត់ថា តើគេឃ្លានដែរឬទេ?
អញ្ចឹងយើងឃើញនៅលើក្មេងប្រុសទី ១ ហ្នឹង គឺយើងឃើញមានចានមីទឹកស៊ុបដដែល
អញ្ចឹងបានន័យថាក្មេងប្រុសទី ១ គាត់កំពុងតែនិយាយប្រាប់មិត្តភក្តិរបស់គាត់អំពីមីទឹកស៊ុប
ដែលគាត់កំពុងតែចង់ញ៉ាំ ដោយសារតែពេលហ្នឹងគឺជាពេលរសៀល អញ្ចឹងគាត់ឃ្លាន
ដោយសារតែអត់ទាន់ដល់ម៉ោងបាយពេលល្ងាច ដូច្នេះគាត់ឃ្លាន
អញ្ចឹងគាត់ក៏បបួលមិត្តភក្តិរបស់គាត់ដើម្បីទៅញ៉ាំមីទឹកស៊ុបទាំងអស់គ្នា។

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ បន្ទាប់ពីពួកគេបបួលគ្នាហើយ
មិត្តភក្តិរបស់គេក៏យល់ព្រម ដោយសារតែមិត្តភក្តិរបស់គេក៏កំពុងតែឃ្លានដូចគ្នា។
អញ្ចឹងបន្ទាប់ពីការងារ ឬក៏ការធ្វើការហាត់នឿយ ឬក៏បន្ទាប់ពីការសិក្សា អញ្ចឹងយើងតែងតែឃ្លាន
ដោយសារតែយើងអស់កម្លាំង អញ្ចឹងនៅពេលដែលយើងអស់កម្លាំង គឺយើងតែងតែឃ្លាន
ដូច្នេះនៅពេលដែលយើងឃ្លាន យើងតែងតែរកអាហារសម្រន់
ដើម្បីញ៉ាំមុនពេលអាហារពេលល្ងាចមកដល់។ អញ្ចឹងជាក់ស្តែងដូចជានៅក្នុងរូបភាពទី ៣ នេះ
គឺក្មេងប្រុសទាំងពីរអ្នកក៏បានបបួលគ្នា ហើយយល់ព្រមទៅញ៉ាំគុយទាវទឹកស៊ុប
ឬក៏មីទឹកស៊ុបទាំងអស់គ្នា ដោយយើងឃើញក្មេងប្រុសទី ១ គាត់ដើរខាងមុខ។ ដែលក្មេងប្រុសទី ១
ហ្នឹង គាត់ស្លៀកពាក់អាវពណ៌សដៃខ្លី ហើយគាត់ស្លៀកខោជើងវែងពណ៌ខ្មៅ ចំណែកឯក្មេងប្រុសទី
២ គឺគាត់ពាក់អាវដៃវែង ពាក់អាវដៃខ្លីពណ៌ស ហើយស្លៀកខោជើងវែងពណ៌សដែរ។
អញ្ចឹងក្មេងប្រុសទី ១ គឺមានសក់រាប ដោយឡែកក្មេងប្រុសទី ២ គឺមានសក់បះ។
អញ្ចឹងពួកគេដើរទៅរកកន្លែងដែលលក់មីទឹកស៊ុប ឬក៏ហាងលក់មីទឹកស៊ុបទាំងអស់គ្នា។
ដោយក្មេងប្រុសទី ១ អ្នកដើរខាងមុខ រីឯក្មេងប្រុសទី ២ ជាអ្នកដើរខាងក្រោយ ហើយក្មេងប្រុសទី ១
គាត់ដើរបណ្តើរ ងាកក្រោយបណ្តើរ ដើម្បីនិយាយជាមួយនឹងក្មេងប្រុសទី ២
ដែលជាមិត្តភក្តិរបស់គាត់។ អញ្ចឹងពួកគេទាំងពីរអ្នកកំពុងតែដើរ ហើយក្មេងប្រុសទី ១ ហ្នឹង
គាត់ងាកមកប្រាប់ក្មេងប្រុសទី ២ ថា គេស្គាល់កន្លែងញ៉ាំទឹកស៊ុបមួយកន្លែង។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺក្មេងប្រុសទី ១ គាត់បានដើរបណ្តើរ ងាកក្រោយបណ្តើរ និងងាកដៃស្តាំរបស់គាត់គឺចង្អុលទៅមុខ។ អញ្ចឹងគាត់ចង់បញ្ជាក់ប្រាប់មិត្តភក្តិរបស់គាត់ថា ហាងលក់គុយទាវ ឬក៏ហាងលក់មីទឹកស៊ុបហ្នឹង គឺនៅខាងមុខ មិនឆ្ងាយនោះទេ ដោយដើរតែបន្តិចទៅដល់ហើយ។ អញ្ចឹងពួកគេទាំងពីរអ្នក ដើរបណ្តើរ និយាយគ្នាបណ្តើរ ដោយនិយាយគ្នាពីហាងទឹកស៊ុបបណ្តើរ ឬក៏និយាយគ្នាអំពីការលេងកីឡា ឬក៏និយាយគ្នាអំពីការសិក្សាជាដើម។ អញ្ចឹងប្រសិនបើយើងទៅញ៉ាំអាហារមានគ្នាច្រើន គឺតែងតែសប្បាយរីករាយ ដោយសារតែយើងអាចជជែកគ្នាលេងបាន។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ ក្រោយពីពួកគេដើរបណ្តើរ និយាយគ្នាបណ្តើរ និងដើរមួយសន្ទុះក្រោយមក យើងឃើញថាពួកគេក៏បានដើរមកដល់កន្លែងលក់មីទឹកស៊ុបមួយកន្លែង ឬក៏កន្លែងលក់គុយទាវទឹកស៊ុបមួយកន្លែង។ ក៏ប៉ុន្តែយើងឃើញនៅក្នុងរូបភាពនេះ គឺពួកគេទាំងពីរនាក់ អត់ទាន់បានចូលទៅរកកន្លែងលក់មីទឹកស៊ុបនោះទេ គឺពួកគេឈរនៅខាងមុខហាងនោះសិន ឬក៏ឈរនៅខាងមុខរទេះលក់មីនោះសិន។ ដោយសារតែរទេះលក់មីនោះ គឺជាកន្លែងដែលលក់នៅតាមចិញ្ចើមថ្នល់ អញ្ចឹងគាត់មិនមែនជាបើកហាងធំ ឬក៏តូបធំនោះទេ គឺគាត់លក់ដោយរទេះ ហើយរទេះរបស់គាត់ គឺនៅចិញ្ចើមថ្នល់។ អញ្ចឹងការលក់នៅចិញ្ចើមថ្នល់ បានន័យថាគាត់លក់នៅក្បែរផ្លូវ ដែលគាត់មិនមែនលក់នៅលើផ្លូវនោះទេ ក៏ប៉ុន្តែគាត់លក់នៅក្បែរៗផ្លូវ ដែលយើងហៅថាចិញ្ចើមថ្នល់។ អញ្ចឹងយើងឃើញនៅខាងក្រោយគាត់ គឺជាស្រមោលនៃទីក្រុងមួយ អញ្ចឹងបានន័យថា គាត់ជាអ្នកដែលរស់នៅទីក្រុងដែរ ក៏ប៉ុន្តែ គាត់ ក្មេងប្រុសទាំងពីរនាក់ គាត់បានចេញពីទីក្រុង ឬក៏ដើរឆ្ងាយពីទីក្រុងបន្តិច ដើម្បីមករកកន្លែងលក់មី។ អញ្ចឹងការលក់មីនេះ គឺជាការលក់មីតាមចិញ្ចើមផ្លូវ ក៏ប៉ុន្តែយើងឃើញថា ទោះបីជាចិញ្ចើមផ្លូវ ក៏ប៉ុន្តែពេលខ្លះ គឺមីនោះគឺមានរសជាតិឆ្ងាញ់ ដោយមិនចាញ់ហាងធំៗនោះទេ ហើយម្យ៉ាងវិញទៀត មីទឹកស៊ុប ឬក៏គុយទាវទឹកស៊ុបដែលលក់នៅតាមចិញ្ចើមផ្លូវ គឺមានតម្លៃថោកជាងនៅក្នុងហាង ក៏ប៉ុន្តែរសជាតិមិនចាញ់គ្នាទេ។ ដែលយើងឃើញនៅក្នុងរូបភាពទី ៤ នេះ យើងឃើញមានស្ត្រីម្នាក់ ដែលគាត់កំពុងតែឈរនៅក្នុងរទេះលក់មី ឬក៏លក់គុយទាវរបស់គាត់ ដោយយើងឃើញនៅក្នុងរទេះនោះគឺមានដំបូលមួយ នៅលើរទេះគឺមានដំបូលមួយ ហើយនៅខាងក្នុងនោះគឺមានចានគោមជាច្រើន ដែលចានគោមគឺជាចានសម្រាប់ដាក់មីទឹកស៊ុប ដោយសារតែចានគោមអាចដាក់ទឹកស៊ុបបាន ដូច្នេះគេប្រើចានគោមដើម្បីដាក់មីទឹកស៊ុប ឬក៏គុយទាវទឹកស៊ុប។ ហើយនៅក្បែរចាននោះយើងឃើញមានឆ្នាំងគុយទាវ ឬក៏ឆ្នាំងមីទឹកស៊ុប ដើម្បី សម្រាប់ធ្វើគុយទាវ ឬក៏ធ្វើមីទឹកស៊ុបឲ្យអតិថិជន។ ដែលយើងឃើញស្ត្រីអ្នកលក់នោះ គាត់បួងសក់ឡើងលើ ហើយគាត់មានពាក់អៀមមួយផងដែរ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីការពារកុំឲ្យប្រឡាក់ខោអាវរបស់គាត់។ អញ្ចឹងយើងឃើញរទេះលក់មីនោះ
គឺជាការលក់មីនៅតាមចិញ្ចើមថ្នល់ ហើយក្មេងប្រុសទាំងពីរ គាត់ដើរមកដើម្បីញ៉ាំមីទឹកស៊ុប
ឬក៏ញ៉ាំគុយទាវទឹកស៊ុបទាំងអស់គ្នា។

បន្ទាប់មកទៀតនៅក្នុងរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញថា
បន្ទាប់ពីពួកគេដើរមកដល់កន្លែងលក់មីហើយ ឬក៏កន្លែងលក់គុយទាវហើយ
ពួកគេក៏បានដើររកតុមួយដើម្បីអង្គុយ។ អញ្ចឹងជាទូទៅកន្លែងលក់មី
ទោះជាបើជាគេលក់ដោយសាររទេះក៏ដោយ
ក៏ប៉ុន្តែគេតែងតែមានកន្លែងអង្គុយត្រឹមត្រូវឲ្យអតិថិជនរបស់គេ ព្រោះថាប្រសិនបើអត់មានតុ
ឬក៏អត់មានកៅអីអង្គុយនោះទេ អតិថិជនរបស់គេនឹងពិបាកញ៉ាំខ្លាំងណាស់។
ដោយគេមិនអាចឈរញ៉ាំបាននោះទេ។ អញ្ចឹងពេលខ្លះអ្នកទិញគឺពេលខ្លះគាត់ទិញខ្ចប់
ដោយការខ្ចប់។ ការខ្ចប់បានន័យថាឲ្យអ្នកលក់គាត់ធ្វើមីទឹកស៊ុប ឬក៏គុយទាវទឹកស៊ុបឲ្យគាត់ហើយ
គាត់យកទៅផ្ទះដើម្បីញ៉ាំ ដោយគាត់ច្រកចូលទៅក្នុងថង់មួយ ឬក៏ចូលទៅក្នុងចានជ័រមួយ
ដើម្បីឲ្យគាត់យួរទៅផ្ទះដើម្បីញ៉ាំ ប៉ុន្តែអ្នកខ្លះទៀតគាត់អត់ចង់យួរទេ ដោយសារផ្ទះគាត់នៅឆ្ងាយ
អញ្ចឹងគាត់ចង់អង្គុយញ៉ាំនៅនឹងកន្លែង បានន័យថាអង្គុយញ៉ាំនៅកន្លែងក្បែរគុយទាវទឹកស៊ុបនោះ
ដូច្នេះអ្នកលក់ត្រូវតែមានតុ និងមានកៅអី សម្រាប់អ្នកទិញ ដើម្បីអង្គុយញ៉ាំ។
ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៥ នេះ យើងឃើញថា អ្នកលក់គុយទាវទឹកស៊ុបនោះ
ទោះបីជាគាត់លក់តាមរទេះក៏ដោយ អញ្ចឹងទោះបីជាគាត់លក់តាមរទេះ ក៏គាត់មានកៅអី
និងមានតុសម្រាប់អតិថិជនរបស់គាត់អង្គុយផងដែរ។ ដែលយើងឃើញនៅក្នុងរូបភាពនេះ
គឺក្មេងប្រុសទាំងពីរ គាត់បានដើរមករកតុមួយ អញ្ចឹងតុនោះគឺមានកៅអីចំនួនពីរផងដែរ
ហើយមានគ្រឿងទេសជាច្រើនដែលនៅលើតុ។ អញ្ចឹងតុដែលគាត់ដើរមករកហ្នឹង គឺអត់ខ្ពស់ទេ
គឺជាកូនតុតូចមួយហើយនិងទាប អញ្ចឹងបានន័យថាល្មមសម្រាប់ការអង្គុយរបស់អតិថិជន
ក្នុងការញ៉ាំ គឺងាយស្រួលញ៉ាំ គាត់អត់ប្រើតុខ្ពស់ទេ គាត់ប្រើតុទាប ជាមួយនឹងកៅអីចំនួនពីរ
ដែលត្រូវនឹងសម្រាប់ពួកគេពីរនាក់ដែលមកញ៉ាំគុយទាវនោះតែម្តង។

បន្ទាប់មកទៀតរូបភាពទី ៦ រូបភាពទី ៦ បន្ទាប់ពីពួកគេបានដើរមកដល់តុដើម្បីអង្គុយហើយ
ពួកគេក៏បានចូលអង្គុយនៅលើកៅអី។ អញ្ចឹងពួកគេអង្គុយទល់មុខគ្នា ដោយពួកគេអង្គុយទល់មុខគ្នា
ដោយក្មេងប្រុសដែលមានសក់បះ ឬក៏ក្មេងប្រុសទី ២ គាត់អង្គុយខាងឆ្វេង ចំណែកឯក្មេងប្រុសទី ១
ដែលស្លៀកខោពណ៌ខ្មៅ គាត់អង្គុយខាងស្តាំ។ ដោយពួកគេទាំងពីរអ្នកគឺអង្គុយទល់មុខគ្នា
ហើយមានកូនតុតូចមួយនៅចំកណ្តាល។ អញ្ចឹងកូនតុតូចនោះ គឺសម្រាប់ដាក់ចានគុយទាវ
ឬក៏ចានមីដើម្បីញ៉ាំ ហើយនៅលើកូនតុនោះគឺយើងឃើញមានគ្រឿងទេសជាច្រើន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគ្រឿងទេសហ្នឹង គឺជាគ្រឿងសម្រាប់ផ្សំរសជាតិ នៅក្នុងការញ៉ាំមីឬក៏ញ៉ាំគុយទាវ អញ្ចឹងពេលណាដែលយើងញ៉ាំ គឺយើងប្រើគ្រឿងទេសដើម្បីផ្សំរសជាតិវាឲ្យបានឆ្ងាញ់បន្ថែមទៀត ដោយសារតែពេលខ្លះទឹកស៊ុបអត់ត្រូវចិត្តរបស់យើងទេ ដូច្នេះយើងត្រូវថែមគ្រឿង ដើម្បីឲ្យចំរសជាតិដែលយើងចូលចិត្ត។ អញ្ចឹងរូបភាពទី ៦ បន្ទាប់ពីក្មេងប្រុសទាំងពីរអ្នក គាត់មកដល់អង្គុយលើតុហើយ គាត់អង្គុយលើកៅអីនៅក្បែរតុនោះហើយ ក្មេងប្រុសទី ១ ក៏បានលើកដៃឡើង អញ្ចឹងគាត់លើកដៃស្តាំគាត់ឡើង ដែលនៅក្នុងរូបភាពនេះ យើងឃើញថាគាត់លើកដៃឡើងដើម្បីជាសញ្ញាហៅអ្នកលក់។ អញ្ចឹងជាទូទៅពេលខ្លះ ប្រសិនបើយើងទៅក្នុងហាង យើងហៅអ្នកលក់អត់ឮទេ ក៏ប៉ុន្តែពេលខ្លះយើង[...] យើងគ្រាន់តែលើកដៃជាសញ្ញា នោះអ្នកលក់មើលឃើញ នៅពេលដែលអ្នកលក់មើលឃើញ អ្នកលក់នឹងមករកយើងជាក់ជាពុំខាន។ ដោយជាក់ស្តែងក្មេងប្រុស[អ្នក]ម្នាក់នេះ គាត់បានលើកដៃឡើង ដើម្បីហៅអ្នកលក់ ក្នុងការធ្វើកុម្ម៉ង់ ក្នុងការកុម្ម៉ង់ ដើម្បីញ៉ាំគុយទាវ ឬក៏ញ៉ាំមី។ អញ្ចឹងនៅក្នុងរូបភាពទី ៦ ក្រោយពីពួកគេបានចូលអង្គុយលើតុហើយ ពួកគេក៏បានហៅអ្នកលក់ដើម្បីកុម្ម៉ង់អាហារញ៉ាំ។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ បន្ទាប់ពីក្មេងប្រុសទាំងពីរនាក់នោះហៅ ឬក៏ក្មេងប្រុសទី ១ គាត់លើកដៃហៅអ្នកលក់ហើយ អ្នកលក់ក៏មកដល់ អញ្ចឹងយើងឃើញអ្នកលក់នៅក្នុងរូបភាពនេះ គឺគាត់ជាមនុស្សស្រី គាត់បួងសក់ឡើងលើ ហើយគាត់ពាក់អៀម ដោយមានពាក់អាវពណ៌សដៃខ្លី ក៏ប៉ុន្តែដោយសារអាវគាត់ស គាត់ខ្លាចប្រឡាក់ ដូច្នេះគាត់ពាក់អៀមពីលើមួយទៀត។ អញ្ចឹងគាត់ចងអៀម ដែលអៀមជាក្រណាត់មួយ សម្រាប់ចងបាំងនៅខាងមុខកុំឲ្យប្រឡាក់ខោអាវ។ អញ្ចឹងអ្នកលក់រៀងធាត់បន្តិច ប៉ុន្តែគាត់ជាស្ត្រីវ័យចំណាស់ ដែលមានអាយុប្រហែលជា ៣០ ឆ្នាំ ហើយគាត់រៀងធាត់បន្តិច។ អញ្ចឹងគាត់មកដល់ដើម្បីសួរទៅដល់ក្មេងប្រុសទាំងពីរថាចង់ញ៉ាំអី ព្រោះថាអម្បាញ់មិញក្មេងប្រុសទាំងពីរនាក់នោះបានហៅគាត់មកដើម្បី[...]ការកុម្ម៉ង់អាហារញ៉ាំ។ អញ្ចឹងគាត់បានសួរទៅក្មេងប្រុសទី ១ ជាមុនសិន ដោយគាត់សួរថាតើប្អូនចង់ញ៉ាំអ្វី ឬក៏ត្រូវការអ្វី? អញ្ចឹងក្មេងប្រុសទី ១ នោះ គាត់ក៏បានប្រាប់ទៅដល់អ្នកលក់ថាគាត់ចង់ញ៉ាំមីដែលមានទឹកស៊ុប ឬក៏គុយទាវទឹកស៊ុប។ អញ្ចឹងក្មេងប្រុសទី ១ គាត់ចង់ញ៉ាំគុយទាវទឹកស៊ុប ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺមានចានគុយទាវទឹកស៊ុបមួយ កំពុងតែហុយ អញ្ចឹងជាធម្មតា គុយទាវទឹកស៊ុប ឬក៏មីទឹកស៊ុប គឺតែងតែក្តៅ ព្រោះគេប្រើទឹកក្តៅដើម្បីឆ្អុងមី ឬក៏ឆ្អុងគុយទាវ។ ដោយអញ្ចឹងប្រសិនបើយើងប្រើទឹកត្រជាក់ ឬទឹកស៊ុបត្រជាក់ គឺអត់ឆ្ងាញ់ទេ គឺបានន័យថាមី ឬក៏គុយទាវនោះ ញ៉ាំអត់កើតទេ ដូច្នេះហើយទើបយើងឃើញមានផ្សែងហុយចេញពីចាន។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ ក្រោយពេលដែលគាត់សួរក្មេងប្រុសទី ១ ហើយ អញ្ចឹងក្មេងប្រុសទី ១ គាត់បានកុម្ម៉ង់មីដែលមានទឹកស៊ុបរួចរាល់ហើយ អ្នកលក់ក៏បានងាកមករកក្មេងប្រុសទី ២ ដើម្បីសួរទៀត។ អញ្ចឹងបន្ទាប់មកទៀតក្មេងប្រុសទី ២ នោះ ក៏បានឆ្លើយថា គាត់ចង់ញ៉ាំគុយទាវដែលអត់ទឹកស៊ុប អញ្ចឹងឬក៏គេហៅថាគុយទាវគោក ឬក៏មីគោក។ អញ្ចឹងជាទូទៅមីគឺមានពីរប្រភេទដែលគេលក់ មិនមែនពីរទេ គឺច្រើនប្រភេទដែរ ដោយយើងឃើញមានទាំងមីឆា មីទឹកស៊ុប មីខ ឬក៏គុយទាវខ ឬក៏គុយទាវទឹកស៊ុបជាដើម។ អញ្ចឹងពេលខ្លះគឺយើងអាចញ៉ាំគុយទាវគោកផងដែរ ដោយមានរសជាតិឆ្ងាញ់ដូចគ្នា តាមចំណង់ចំណូលចិត្តអ្នកញ៉ាំ។ អញ្ចឹងអ្នកខ្លះគាត់ចូលចិត្តទឹកស៊ុប អ្នកខ្លះគាត់អត់ចូលចិត្តទឹកស៊ុបទេ គឺគាត់ចូលចិត្តញ៉ាំមីគោក ដែលយើងហៅថាមីគោក។ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ៨ នេះ ក្មេងប្រុសទី ២ គាត់អត់ចូលចិត្តញ៉ាំគុយទាវ ឬក៏មីទឹកស៊ុបនោះទេ ក៏ប៉ុន្តែគាត់ចូលចិត្តញ៉ាំមីគោក ដូច្នេះគាត់ក៏បានប្រាប់ទៅអ្នកលក់ថាគាត់ចង់ញ៉ាំមីគោក។

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ បន្ទាប់ពីគាត់កុម្ម៉ង់រួចរាល់ហើយ អញ្ចឹងគាត់កុម្ម៉ង់រួចរាល់ហើយ អ្នកលក់ក៏បានយកកែវទឹកចំនួនពីរ ដើម្បីមកឲ្យពួកគាត់ទាំងពីរនាក់។ អញ្ចឹងនៅក្នុងរូបភាពទី ៩ នេះ យើងឃើញអ្នកលក់គាត់បានកាន់កែវទឹកចំនួនពីរ ដែលកែវទឹកនោះមានទឹកកកនៅក្នុងនោះផងដែរ។ អញ្ចឹងគេដាក់ទឹកកកចូលទៅក្នុងកែវទាំងពីរ ហើយមានបំពង់បឺតពីរនៅក្នុងកែវនីមួយៗ អញ្ចឹងបានន័យថាកែវមួយមានបំពង់បឺតមួយ កែវមួយទៀតមានបំពង់បឺតមួយ។ ដោយសារតែកន្លែងនោះគឺជាកន្លែងលក់សាធារណៈ បានន័យថាមានអតិថិជនច្រើន អញ្ចឹងមានអតិថិជនច្រើន ដូច្នេះការប្រើប្រាស់កែវ គឺជាការប្រើប្រាស់កែវរួម អញ្ចឹងហើយដើម្បីរក្សាអនាម័យ គឺអ្នកលក់ គាត់អត់ឲ្យអតិថិជនរបស់គាត់ញ៉ាំផ្ទាល់ទៅនឹងកែវនោះទេ អញ្ចឹងគេអត់ញ៉ាំផ្ទាល់ទេខ្លាចឆ្លងមេរោគ ដូច្នេះក្នុងការញ៉ាំទឹកនៅកែវនោះ គឺគេត្រូវប្រើបំពង់បឺត។ អញ្ចឹងនៅក្នុងរូបភាពនេះ គាត់បានដាក់បំពង់បឺតចូលទៅក្នុងកែវទាំងពីរ ដើម្បីឲ្យអតិថិជនរបស់គាត់ញ៉ាំទឹក ដោយប្រើបំពង់បឺតវិញ ដោយគេញ៉ាំហើយគេបោះចោលបំពង់បឺតនោះតែម្តង ហើយគេដាក់ទឹកកកនៅក្នុងកែវ ដើម្បីឲ្យនៅពេលដែលយើងដាក់ទឹក គឺទឹកកកនឹងធ្វើឲ្យទឹកនោះត្រជាក់។ អញ្ចឹងជាទូទៅការមកញ៉ាំបែបនេះ គឺតែងតែត្រូវការទឹកកក ឬក៏ទឹកត្រជាក់ ដូច្នេះហើយអ្នកលក់តែងតែដាក់ទឹកកកចូលទៅក្នុងកែវឲ្យអតិថិជនរបស់គាត់។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ បន្ទាប់ពីគាត់បានទទួលកែវទឹកចំនួនពីរហើយ អញ្ចឹងបន្ទាប់ពីគាត់បានទទួលកែវទឹកចំនួនពីរហើយ ក្មេងប្រុសទាំងពីរនាក់នោះ ក៏យកកែវទឹកនោះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យកមកដាក់លើតុ បន្ទាប់មកគេក៏គាស់ទឹកក្រូចមួយកំប៉ុង អញ្ចឹងទឹកក្រូចមួយកំប៉ុង ដើម្បីចាក់ចូលទៅក្នុងកែវទាំងពីរនោះ។ អញ្ចឹងដោយសារតែពួកគេអត់សូវចង់ចំណាយលុយច្រើន អញ្ចឹងគេប្រើ គេញ៉ាំទឹកក្រូចមួយកំប៉ុងពីរនាក់តែម្តង។ ដោយនៅក្នុងរូបភាពនេះ យើងឃើញគេចាក់ទឹកក្រូចចូលទៅក្នុងកែវទាំងពីរដែលមានទឹកកកស្រាប់។ អញ្ចឹងនៅពេលដែលទឹកក្រូចចាក់ចូលទៅក្នុងកែវដែលមានទឹកកក វានឹងធ្វើឲ្យទឹកក្រូចនោះត្រជាក់ អញ្ចឹងទឹកក្រូចត្រជាក់គឺមានរសជាតិកាន់តែឆ្ងាញ់។ ហើយពួកគេក៏យកកែវនោះមកញ៉ាំ ប៉ុន្តែពួកគេអត់ញ៉ាំដោយនឹងផ្ទាល់មាត់ទៅនឹងកែវទេ គឺគេញ៉ាំដោយប្រើប្រាស់បំពង់បឺត។ អញ្ចឹងនៅក្នុងរូបភាពទី ១០ នេះ យើងឃើញគេកំពុងតែចាក់ទឹកក្រូចចូលទៅក្នុងកែវទាំងពីរ ដោយបរិមាណស្មើៗគ្នា។ អញ្ចឹងពួកគេទាំងពីរនាក់ គឺចែកគ្នាស្មើ បានន័យថាពាក់កណ្តាលម្នាក់ អញ្ចឹងនៅពេលដែលទឹកក្រូចពេញកំប៉ុង គឺគេចាក់ពាក់កណ្តាលទៅក្នុងកែវទី ១ ហើយពាក់កណ្តាលទៀតគេចាក់ទៅក្នុងកែវទី ២ ដោយពួកគេទាំងពីរអ្នកគឺចាក់ស្មើៗគ្នា ដូច្នេះពួកគេអត់ចាំបាច់ចំណាយលុយច្រើន ដើម្បីទិញទឹកក្រូចពីរកំប៉ុងនោះទេ។ អញ្ចឹងដោយសារតែទឹកក្រូចគឺច្រើនល្មមសម្រាប់គ្នាពីរនាក់ញ៉ាំដែរ ដូច្នេះគេទិញតែមួយកំប៉ុងដើម្បីញ៉ាំពីរអ្នកតែម្តង។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ គឺបន្ទាប់ពីពួកគេអង្គុយរង់ចាំបានបន្តិច ដោយពួកគេចាក់ទឹកក្រូចដើម្បីញ៉ាំហើយ មួយសន្ទុះក្រោយមក អ្នកលក់ក៏បានត្រលប់មកតុរបស់ពួកគេទាំងពីរនាក់វិញ។ អញ្ចឹងម្តងនេះគឺអ្នកលក់មកទាំង ដៃទាំងគាត់ទាំងសងខាងគឺកាន់មីចំនួនពីរចាន ឬក៏គុយទាវចំនួនពីរចាន។ ដោយនៅក្នុងរូបភាពនេះយើងឃើញ អ្នកលក់គាត់បានកាន់ចានមីទឹកស៊ុបនៅក្នុងដៃឆ្វេងរបស់គាត់ ហើយចានមីគោកនៅក្នុងដៃស្តាំរបស់គាត់។ អញ្ចឹងចានមីទាំងពីរគឺក្តៅ គឺកំពុងតែក្តៅ បានន័យថាយើងឃើញមានផ្សែងហុយៗចេញពីចាន អញ្ចឹងក្តៅផង និងមានក្លិនឈ្ងុយផង ព្រោះជាទូទៅ មីទឹកស៊ុប ឬក៏គុយទាវទឹកស៊ុប គឺតែងតែមានក្លិនទឹកស៊ុបឈ្ងុយ ដែលហិតទៅគឺគួរឲ្យចង់ញ៉ាំមែនទែន ហើយចាន ដោយសារតែក្តៅៗផង ដូច្នេះរសជាតិវាគឺកាន់តែឆ្ងាញ់តែម្តង។ អញ្ចឹងនៅក្នុងរូបភាពទី ១១ នេះ គឺអ្នកលក់គាត់បានធ្វើមី ឬក៏ធ្វើគុយទាវទឹកស៊ុបឆ្អិនហើយ ដូច្នេះគាត់ក៏បានដួសដាក់ចាន ដើម្បីយកមកឲ្យអតិថិជនរបស់គាត់ ដែលជាក្មេងប្រុសទាំងពីរនាក់នោះ ដើម្បីញ៉ាំតែម្តង។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថា បន្ទាប់ពីពួកគេទាំងពីរនាក់ ឬក៏ក្មេងប្រុសទាំងពីរនាក់ គាត់បានទទួលចានមីទឹកស៊ុបរបស់គាត់ដែលបានកុម្ម៉ង់រួចរាល់ហើយ អញ្ចឹងពួកគេក៏បានទទួលពីអ្នកលក់ ដោយអ្នកលក់យកចានទាំងពីរនោះមកដាក់លើតុរបស់ពួកគេ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយដាក់ចានគុយទាវទឹកស៊ុបឲ្យក្មេងប្រុសទី ១ និងចានគុយទាវគោក
ឬក៏មីគោកទៅឲ្យក្មេងប្រុសទី ២ ដើម្បីញ៉ាំ។ អញ្ចឹងបន្ទាប់ពីពួកគេបានទទួលមីគោក
ហើយនិងមីទឹកស៊ុបហើយ នៅក្នុងរូបភាពទី ១២ ពួកគេក៏បានយកចង្កឹះមក។ អញ្ចឹងជាធម្មតា
ការលក់នៅតាមចិញ្ចើមផ្លូវគឺតែងតែមានដីហុយ អញ្ចឹងចង្កឹះ និងស្លាបព្រា
ប្រសិនបើយើងអត់រក្សាអនាម័យទេ វានឹងប្រឡាក់ដីមិនខាន
ដូច្នេះជាធម្មតាចង្កឹះគេដាក់នៅក្នុងស្រោមមួយ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ១២ នេះ
ពួកគេក៏បានហែកស្រោមចង្កឹះ ដើម្បីដកចង្កឹះចេញពីស្រោម។ ដែលស្រោមចង្កឹះ
ពេលខ្លះគឺធ្វើពីថង់ប្លាស្ទិក ហើយពេលខ្លះទៀតគេធ្វើអំពីក្រដាស អញ្ចឹងស្រោមចង្កឹះនេះ
គឺបានរុំចង្កឹះកុំឲ្យប្រឡាក់ដី ព្រោះថាពេលខ្លះការលក់បែបនេះគឺមានដីហុយ ដោយសារតែមានឡាន
ម៉ូតូ គាត់បើកតាមផ្លូវច្រើន អញ្ចឹងធ្វើឲ្យដីហុយប្រឡាក់
ដូច្នេះហើយទើបគាត់ដាក់ក្នុងស្រោមដើម្បីរក្សាអនាម័យ ប្រសិនបើអត់រក្សាអនាម័យទេ
អតិថិជនរបស់គាត់អាចឈឺ ដោយសារឆ្លងមេរោគ ដោយសារមានធូលីជាប់នឹងចង្កឹះជាដើម។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣ យើងឃើញថា
បន្ទាប់ពីគាត់ហែកស្រោមចង្កឹះហើយ យើងឃើញពួកគេទាំងពីរនាក់ក៏បានបើកប្រអប់មួយ
អញ្ចឹងនៅលើតុរបស់ពួកគេក៏មានប្រអប់មួយដែរ សម្រាប់ដាក់ស្លាបព្រា
អញ្ចឹងប្រអប់នោះគឺជាប្រអប់សម្រាប់ដាក់ស្លាបព្រា ដើម្បីរក្សាអនាម័យកុំឲ្យស្លាបព្រានោះប្រឡាក់ដី
ដូច្នេះហើយ អ្នកលក់ក៏បានយកស្លាបព្រាទៅដាក់ក្នុងប្រអប់បិទជិតមួយ។
អញ្ចឹងប្រសិនបើគាត់ដាក់ក្នុងប្រអប់បិទជិត គឺដីអត់ហុយចូលទេ។
ដោយដីទាំងអស់នោះគឺអត់ហុយចូលប្រអប់ទេ អញ្ចឹងប្រអប់របស់គាត់អត់ប្រឡាក់នោះទេ។
អញ្ចឹងពួកគេទាំងពីរនាក់ ក៏បានបើកប្រអប់មួយដើម្បីយកស្លាបព្រាចេញពីប្រអប់នោះ។
ហើយបន្ទាប់មកយើងឃើញនៅក្នុងរូបភាពទី ១៣ ដដែល
បន្ទាប់ពីពួកគេយកស្លាបព្រាចេញពីប្រអប់នោះហើយ
ពួកគេក៏បានយកស្លាបព្រានោះមកជូតនឹងក្រដាសអនាម័យ។
អញ្ចឹងជាទូទៅនៅលើតុគុយទាវតែងតែមានក្រដាសអនាម័យមួយប្រអប់ផងដែរ
ដើម្បីឲ្យអតិថិជនជូតចង្កឹះ និងជូតស្លាបព្រារបស់ពួកគេ។ អញ្ចឹងជាទូទៅយើងញ៉ាំមី
ឬក៏ញ៉ាំគុយទាវដោយប្រើចង្កឹះ ក៏ប៉ុន្តែស្លាបព្រាគឺយើងយកដើម្បីហុតទឹកស៊ុប។
អញ្ចឹងនៅក្នុងរូបភាពនេះ ក្មេងប្រុសទី ១ គាត់ក៏បានយកស្លាបព្រា ដើម្បីជូតសម្អាត
ដើម្បីធ្វើការហុតទឹកស៊ុបរបស់គាត់ ដោយសារតែគាត់កុម្ម៉ង់មីមានទឹកស៊ុប។
អញ្ចឹងដើម្បីឲ្យប្រាកដថាស្លាបព្រានោះស្អាត គឺត្រូវជូតបន្ថែមទៀតដោយប្រើក្រដាសអនាម័យ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញថា
បន្ទាប់ពីគាត់បានទទួលចានមីទាំងអស់ហើយ ក្មេងប្រុសទី ១ ក្មេងប្រុសទី ១
ដែលបានកុម្ម៉ង់មីមានទឹកស៊ុបហ្នឹង គាត់ក៏បានបន្ថែមគ្រឿងចូលទៅក្នុងចានមីរបស់គាត់
ដែលនៅក្នុងរូបភាពទី ១ នេះ យើងឃើញគាត់បានបន្ថែមដូចជាម្ទេស
អញ្ចឹងដោយសារតែគាត់ចូលចិត្តរសជាតិហឹរ។ អញ្ចឹងរូបភាពទី ១៤ នេះ គឺនៅខាងឆ្វេងដៃ
រូបភាពខាងឆ្វេងដៃគឺគាត់កំពុងតែថែមម្ទេស ចូលទៅក្នុងចានមីរបស់គាត់
ដោយយើងឃើញគាត់ដាក់ម្ទេសមួយស្លាបព្រាតូច ឬក៏មួយកូនស្លាបព្រាដើម្បីញ៉ាំ។ បន្ទាប់មកទៀត
រូបភាពទី ១៤ ដែលនៅខាងស្ដាំដៃ គឺគាត់ក៏បន្ថែមទឹកខ្មេះចូលផងដែរ។
អញ្ចឹងទឹកខ្មេះគឺមានរសជាតិជូរ ដូច្នេះប្រសិនបើគាត់ដាក់ទឹកខ្មេះ និងដាក់ម្ទេស
បានន័យថាគាត់ចូលចិត្តរសជាតិជូរនិងហឹរ។ អញ្ចឹងទឹកខ្មេះ គឺជូរដូចក្រូចឆ្មារដែរ
ពេលខ្លះយើងប្រើក្រូចឆ្មារ ក៏ប៉ុន្តែពេលខ្លះយើងប្រើទឹកខ្មេះដើម្បីលាយផ្សំគ្រឿង
ដែលជាក់ស្ដែងនៅក្នុងរូបភាពនេះ គេអត់ប្រើក្រូចឆ្មារទេ គឺគេប្រើទឹកខ្មេះជំនួសក្រូចឆ្មារវិញ
ក៏ប៉ុន្តែវាមានរសជាតិជូរដូចគ្នា ដោយម្ទេសមានរសជាតិហឹរ និងទឹកខ្មេះមានរសជាតិជូរ។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ យើងឃើញមាន ៣ រូបភាពផងដែរ
ដែលរូបភាពនៅខាងឆ្វេងដៃ គឺក្មេងប្រុសដដែលនោះ
គាត់ក៏បានចាក់ទឹកត្រីចូលទៅក្នុងចានមីរបស់គាត់ទៀត។ អញ្ចឹងដោយសារតែមី ឬក៏ទឹកស៊ុប
ឬក៏គុយទាវទឹកស៊ុបដែលគាត់បានកុម្ម៉ង់ហ្នឹង គឺរសជាតិអត់ទាន់ត្រូវចិត្តគាត់ទេ
ព្រោះពេលខ្លះអ្នកលក់គាត់អត់ធ្វើឲ្យមានរសជាតិប្រៃពេក ឬក៏ផ្អែមពេកនោះទេ
គឺគាត់ធ្វើតម្រូវឲ្យអតិថិជន ដើម្បីឲ្យគាត់ថែមគ្រឿងខ្លួនឯង។
ព្រោះថាពេលខ្លះប្រសិនបើគាត់ធ្វើប្រៃពេក អតិថិជនរបស់គាត់ញ៉ាំសាប គឺញ៉ាំអត់កើតទេ
បានន័យថាអត់ឆ្ងាញ់ អញ្ចឹងគាត់ត្រូវតែធ្វើសាបល្មម ដើម្បីនៅពេលដែលអតិថិជនគិតថាមិនត្រូវចិត្ត
គេអាចថែមគ្រឿងបាន ដោយគ្រឿង អ្នកលក់បានដាក់នៅលើតុស្រាប់
ដែលជាក់ស្ដែងក្មេងប្រុសម្នាក់នេះ គាត់បានថែមគ្រឿងជាច្រើនចូលទៅក្នុងចានរបស់គាត់
ដើម្បីឲ្យត្រូវតាមរសជាតិដែលគាត់ចង់បាន។ ដោយរូបភាពទី ១៥ នេះ
គាត់ក៏បានថែមទឹកត្រីចូលបន្តិច ដើម្បីឲ្យមានរសជាតិប្រៃ បន្ទាប់មករូបភាពនៅកណ្ដាល
គាត់បានថែមស្ករសមួយកូនស្លាបព្រាទៀត អញ្ចឹងដើម្បីឲ្យមានរសជាតិកាន់តែឆ្ងាញ់
គាត់ថែមស្ករសបន្ថែមទៀត។ ដោយគាត់បានបន្ថែមនូវម្ទេស គាត់បានបន្ថែមនូវទឹកខ្មេះ
ហើយគាត់បានចាក់នូវទឹកត្រីបន្តិច និងស្ករសបន្តិចដើម្បីចូលទៅក្នុងចានគុយទាវរបស់គាត់
ដើម្បីឲ្យមានរសជាតិកាន់តែឆ្ងាញ់តាមអ្វីដែលគាត់ចង់បាន។ បន្ទាប់មករូបភាពទី ១៥ ដដែល
ដែលនៅខាងឆ្វេង នៅខាងស្ដាំដៃ គឺបន្ទាប់ពីគាត់លាយគ្រឿងទាំងអស់ចូលគ្នារួចហើយ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានយកចង្កឹះមកកូរច្របល់វា ដើម្បីឲ្យរសជាតិចូលគ្នាទៅក្នុងមីនោះសព្វ។
អញ្ចឹងប្រសិនបើយើងអត់កូរ ឬក៏ច្របល់មីទឹកស៊ុបនោះទេ
រសជាតិរបស់វានឹងអត់ចូលជាតិសព្វនោះទេ បានន័យថាកន្លែងខ្លះនឹងជូរ កន្លែងខ្លះនឹងប្រៃ
ហើយកន្លែងខ្លះនឹងផ្អែម ហើយកន្លែងខ្លះហឹរ គឺអត់ស្មើសាច់ទេ
អញ្ចឹងដើម្បីឲ្យវាមានរសជាតិស្មើគ្នាគ្រប់កន្លែង យើងត្រូវកូរវាឲ្យសព្វសិន
ដើម្បីឲ្យគ្រឿងរលាយចូលទៅក្នុងទឹកស៊ុប និងចូលជ្រាបសព្វទៅក្នុងសាច់មី
ដូច្នេះហើយទើបយើងត្រូវកូរវាឲ្យបានសព្វ ដែលជាក់ស្តែងនៅក្នុងរូបភាពទី ១៥
ដែលនៅខាងស្តាំដៃនេះ គឺគេកំពុងតែកូរមី ឬក៏កូរគុយទាវឲ្យជាមួយនឹងទឹកស៊ុបឲ្យបានសព្វ
ដើម្បីឲ្យគ្រឿងរលាយចូលសព្វទាំងអស់មុននឹងធ្វើការញ៉ាំ។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦
បន្ទាប់ពីក្មេងប្រុសទាំងពីរនាក់បានលាយគ្រឿងមីរបស់គេរួចរាល់ហើយ
អញ្ចឹងគេលាយគ្រឿងមីរបស់គេរួចរាល់ អញ្ចឹងបានន័យថា ត្រូវនឹងរសជាតិអ្វីដែលគេចង់បានហើយ
ពួកគេក៏ចាប់ផ្តើមញ៉ាំមីទាំងនោះ ដោយក្មេងប្រុសទី ១ គាត់ញ៉ាំមីមានទឹកស៊ុប ចំណែកក្មេងប្រុសទី
២ គាត់ញ៉ាំមីអត់ទឹកស៊ុប ឬក៏មីគោក ហើយយើងឃើញពួកគេទាំងពីរនាក់ គឺប្រើចង្កឹះម្នាក់មួយគូ
ដើម្បីចាប់សរសៃមីឡើងញ៉ាំ។ អញ្ចឹងដោយសារតែសរសៃមីវែង ដោយសារតែសរសៃមីវែង
ដូច្នេះយើងឃើញគេប្រើចង្កឹះ ហើយមី សរសៃមីនៅក្នុងមាត់
ហើយចុងម្ខាងនៃសរសៃមីគឺនៅក្នុងចាន។ អញ្ចឹងគឺវាពេលខ្លះ ប្រសិនបើយើងអត់ចេះញ៉ាំ
គឺពិបាកញ៉ាំណាស់ ដោយសារតែវាវែងពេក អញ្ចឹងពេលខ្លះគេត្រូវប្រើចង្កឹះ
ដើម្បីកាត់ផ្តាច់សរសៃមីឲ្យខ្លី ហើយពេលខ្លះទៀតយើងប្រើធ្មេញ ដើម្បីខាំផ្តាច់សរសៃមី។
អញ្ចឹងនៅពេលដែលយើងដាក់សរសៃមីចូលក្នុងមាត់បានខ្លះហើយ យើងប្រើធ្មេញរបស់យើង
ដើម្បីខាំសរសៃមីទម្លាក់ចូលក្នុងចានវិញ។ អញ្ចឹងសរសៃមីណាដែលនៅក្រៅមាត់
គឺវាធ្លាក់ចូលទៅក្នុងចាន ចំណែកឯសរសៃមីដែលនៅក្នុងមាត់ គឺយើងទំពាញ៉ាំតែម្តង។
ដែលជាក់ស្តែងនៅក្នុងរូបភាពនេះ ក្មេងប្រុសទាំងពីរនាក់
គាត់បានបៀមសរសៃមីនៅក្នុងមាត់របស់គាត់ ហើយប្រើចង្កឹះដើម្បីកាត់សរសៃមីនោះឲ្យខ្លី
ដើម្បីងាយស្រួលញ៉ាំ ព្រោះប្រសិនបើយើងអត់កាត់ឲ្យខ្លីទេ យើងអាចស្លាក់បាន
អញ្ចឹងនៅពេលដែលមីវែងពេក នៅពេលដែលយើងលេបទៅវាអត់ផុតមាត់ ឬក៏អត់ផុតបំពង់ក
ដូច្នេះវាអាចធ្វើឲ្យយើងស្លាក់បាន អញ្ចឹងយើងត្រូវកាត់វាឲ្យខ្លីៗសិន ដើម្បីងាយស្រួលញ៉ាំ។

បន្ទាប់មកទៀតរូបភាពទី ១៧ នៅក្នុងរូបភាពទី ១៧ យើងឃើញថា
បន្ទាប់ពីក្មេងប្រុសទាំងពីរគាត់បានញ៉ាំហើយ យើងឃើញក្មេងប្រុសទី ១

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់ក៏បានចាប់ផ្ដើមបែកញើស និងឡើងមុខក្រហម ដោយសារតែមីទឹកស៊ុបក្ដៅផង
ដោយសារតែវាក្ដៅ ហើយម្យ៉ាងទៀត គាត់បានដាក់ម្ទេសចូលទៅក្នុងមីរបស់គាត់។
អញ្ចឹងម្ទេសគឺមានរសជាតិហឹរ នៅពេលដែលហឹរគឺធ្វើឲ្យយើងក្ដៅខាងក្នុង
ធ្វើឲ្យយើងបែកញើសច្រើន និងនៅពេលដែលយើងហឹរខ្លាំង គឺមុខរបស់យើងនឹងឡើងក្រហម
ដោយសារតែយើងហឹរខ្លាំងពេក និងក្ដៅខ្លាំងពេក។ ដូច្នេះនៅក្នុងរូបភាពនេះ
យើងឃើញគាត់មានបែកញើស ហើយមុខរបស់គាត់ឡើងពណ៌ក្រហម អញ្ចឹងគាត់ត្រូវការញ៉ាំទឹក
ព្រោះនៅពេលដែលយើងហឹរខ្លាំង គឺយើងញ៉ាំទឹកគឺវាអាចកាត់បន្ថយភាពហឹររបស់យើង
ឬក៏កាត់បន្ថយភាពក្ដៅរបស់យើងបាន ដែលជាក់ស្ដែងក្មេងប្រុសម្នាក់នេះ គាត់កំពុងតែញ៉ាំទឹក
ដើម្បីកាត់បន្ថយការហឹររបស់គាត់។
ដោយយើងឃើញគាត់យកកែវទឹករបស់គាត់មកកាន់នៅដៃខាងឆ្វេងរបស់គាត់
គាត់ប្រើដៃខាងស្ដាំកាន់កែវទឹក ហើយមាត់របស់គាត់ក៏បានបឺតទុយោទឹក ឬក៏បឺតបំពង់បឺត
ដើម្បីបឺតទឹកកកចូលទៅក្នុងពោះរបស់គាត់។ អញ្ចឹងគាត់បឺតទឹកកកចេញពីកែវទឹកកក
ដែលគាត់ចាក់ទឹកក្រូចអម្បាញ់មិញ អញ្ចឹងគាត់បឺតទឹកក្រូចដែលត្រជាក់នោះចេញពីកែវ ដើម្បីញ៉ាំ
ដើម្បីកាត់បន្ថយការហឹរ និងដើម្បីកាត់បន្ថយភាពក្ដៅ ដោយសារតែគាត់ញ៉ាំម្ទេស
និងញ៉ាំមីទឹកស៊ុបដែលមាន ដែលក្ដៅ កំពុងក្ដៅ ហើយនិងញ៉ាំម្ទេសដែលមានរសជាតិហឹរ។

បន្ទាប់មកទៀតរូបភាពទី ១៩ រូបភាពទី ១៨ នៅក្នុងរូបភាពទី ១៨ យើងឃើញ
បន្ទាប់ពីពួកគេញ៉ាំហើយ ពួកគេក៏បានឲ្យលុយទៅអ្នកលក់ អញ្ចឹងជាទូទៅក្រោយពេលដែលយើង
ក្រោយពេលដែលញ៉ាំ គឺយើងតែងតែឲ្យលុយទៅអ្នកលក់ គឺអត់សូវឲ្យលុយមុនពេលញ៉ាំនោះទេ
អញ្ចឹងបន្ទាប់ពីញ៉ាំរួច យើងក៏ហៅអ្នកលក់មកដើម្បីគិតលុយ
ដោយពួកគេក៏បានហៅអ្នកលក់ដើម្បីមកគិតលុយ បន្ទាប់មកអ្នកលក់ក៏បានមក
ហើយប្រាប់គេអំពីតម្លៃមីទាំងពីរចាន ដោយតម្លៃមីគោកផ្សេង និងតម្លៃមីមានទឹកស៊ុបផ្សេងគ្នា
ដូច្នេះក្រោយពីបានដឹងតម្លៃមីទាំងពីរចាននោះហើយ ពួកគេក៏បានហុចលុយឲ្យទៅអ្នកលក់
ដើម្បីបង់ថ្លៃមី ឬក៏ថ្លៃគុយទាវរបស់គេដែលបានញ៉ាំ។ អញ្ចឹងនៅក្នុងរូបភាពនេះ
យើងឃើញក្មេងប្រុសទី ១ គាត់បានហុចលុយទៅឲ្យអ្នកលក់មួយចំនួន
ទៅតាមថ្លៃមីដែលពួកគេបានញ៉ាំ ហើយអ្នកលក់គាត់បានលើកដៃពីរទាំងញញឹម
ហើយទទួលយកលុយនោះ។ អញ្ចឹងជាទូទៅអ្នកលក់
គឺតែងតែមានទឹកមុខញញឹមស្វាគមន៍អតិថិជនជានិច្ច។ ដោយប្រសិនបើគាត់អត់ញញឹមទេ
អតិថិជនរបស់គាត់អាចនឹងមិនពេញចិត្ត ហើយលែងមកញ៉ាំនៅទីនេះទៀត
ដូចនេះគាត់ត្រូវតែរាក់ទាក់ជាមួយអតិថិជនដោយស្នាមញញឹម និងគួរសមជាទីបំផុត។
ដែលជាក់ស្ដែងនៅក្នុងរូបភាពទី ១៨ គឺអ្នកលក់គាត់បានទទួលលុយពីអតិថិជនទាំងញញឹម

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយនិយាយថាអរគុណ ថ្ងៃក្រោយអញ្ជើញមកទៀត។ ដូច្នេះអ្នក អ្នកទិញនឹងថ្ងៃក្រោយ
នៅពេលដែលគាត់លក់ឆ្ងាញ់ នៅពេលដែលគុយទាវគាត់ឆ្ងាញ់
អញ្ចឹងអ្នកទិញនឹងអាចមកម្តងទៀតនៅថ្ងៃក្រោយជាក់ជាពុំខាន
ដូច្នេះអ្នកលក់ត្រូវតែរាក់ទាក់គេយ៉ាងយកចិត្តទុកដាក់ និងគួរសមជាទីបំផុត។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.